ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚៛៛៚៛៛៚

តុលាការកំពូល

៛៛៚

សភាជំនុំជម្រះរឿងរដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ ១០៣

ចុះថ្ងៃទី០១ខែមិនាឆ្នាំ២០០០

សាលដីកា

លេខ : ១៤

ចុះថ្ងៃទី១៨ខែមករាឆ្នាំ២០០១

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០១ ដោយមានសមាសភាពដូចខាងក្រោម

១_ ឯកឧត្តម ឌិត មុន្ធី ជាប្រធាន

២_ លោក ម៉ែន ស៊ុន ជាចៅក្រម

៣_ លោក ជីវ កេង ជាចៅក្រម

៤_ លោក ស៊ិន ឌឹម ជាចៅក្រមរបាយការណ៍

ជំនួសលោក វៀល មួន

៥_ លោក យស់ សួខៀន ជាចៅក្រម

ក្រឡាបញ្ជី

លោក អ៊ុំ សុផុន

លោក ម៉ែន សាខឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ៤៥៨ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ១៩៩៩ នៃសាលាឧទ្ធរណ៍ ពីសាលក្រមរដ្ឋប្បវេណីលេខ ៣១១ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខ យួន សេង អាយុ ៣៨ឆ្នាំ ជាតិ ខ្មែរ មុខរបរគ្រូពេទ្យ ទីលំនៅសព្វថ្ងៃ ក្រុម១១ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ឈ្មោះ យួន សេង បានផ្ទេរសិទ្ធិអោយឈ្មោះ តាន់ អេង ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ ម៉ែន សម្បត្តិ តំណាងអោយឈ្មោះលីប៊ុនឈៀងជា ចំណាំ ឌុច អ៊ីម និង ឈ្មោះ លីម គឹមស៊ា ទីលំនៅ ភូមិព្រែកមហាទេព ឃុំ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងសុំអោយអនុវត្តតាមកិច្ចសន្យាសំរុះសំរួលចុះថ្ងៃទី២៧.៦.១៩៩៧ ។

តាមបណ្តឹងសាទុក្ខលេខ ៣៥៩ ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ឈ្មោះ តាន់ អេង បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៤៥៨ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

--- ---

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១០៣ ចុះថ្ងៃទី ០១ ខែ មិនា ឆ្នាំ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៣.៥.៩៨ លោក ម៉ែន សម្បត្តិ , លី ប៊ុនឃៀង , ឌុក អ៊ុម , ជាចំណាង និង ឈ្មោះ លឹម គីមស៊ារ បញ្ជាក់ថា : យើងប្តឹងសុំអោយចុងចម្លើយ លោក យួន សេង អោយគោរព និង អនុវត្តតាមកិច្ចសន្យាសំរុះសំរួលរបស់គណៈកម្មាធិការ ជំនាញចំរុះខេត្តចុះថ្ងៃទី ២៧.៦.៩៧ ស្តីពីការសាងសង់ និង ប្តឹងសុំអោយចុងចម្លើយបន្ទាបដំបូល ស័ង្កសី ជញ្ជាំងហ៊ីប្រូស៊ីម៉ងត៍ចុះមកក្រោមពីព្រោះថា យើងបានធ្វើកិច្ចសន្យាព្រមព្រៀងជាមួយ ចុងចម្លើយនៅចំពោះមុខគណៈកម្មាធិការជំនាញចំរុះខេត្តស្តីពីការសាងសង់នេះរួចហើយ តែដល់ ពេលសាងសង់ចុងចម្លើយពុំព្រមអនុវត្តតាមគោលការណ៍សាងសង់នេះទៀយ ដោយចុងចម្លើយរៀប ជញ្ជាំងពីឥដ្ឋ ប្លុកស៊ីម៉ងត៍ទៅវិញ ។

បានឃើញដីកាសំរេចកិច្ចការប្រញាប់លេខ ៧១៥ ចុះថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ ១៩៩៨ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលពាក្យបណ្តឹងសុំកិច្ចការប្រញាប់ចុះថ្ងៃទី ១៦.៦.១៩៩៨ របស់ដើម ចោទឈ្មោះ ម៉ែន សម្បត្តិ ប្តឹងសុំអោយចុងចម្លើយឈ្មោះ យួន សេង ផ្អាកសកម្មភាពការសាងសង់ សំណង់តាមកំណត់ព្រំនៃផ្ទះល្វែងទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២_ អោយចុងចម្លើយឈ្មោះ យួន សេង ជួសជុលបិទជញ្ជាំងត្រង់ចំនុចធ្លុះធ្លាយ បើកន្លែងពីខាងក្រៅ ដោយអោយរក្សាសំណៅដែលបែកនៅដដែល តាមការឯកភាពរបស់ គូភាគី ។

៣_ អោយចុងចម្លើយឈ្មោះ យួន សេង រក្សាទ្វារដែកទើបធ្វើថ្មីខាងក្នុងបន្ទប់ នៅដដែល តាមការឯកភាពរបស់គូភាគី ។

៤_ ហាមដាច់ខាតមិនអោយគូភាគីសាងសង់សំណង់ថ្មីផ្សេងៗ លើទីតាំងដែលកំពុង មានទំនាស់ក្នុងសំណុំរឿងនៃអង្គសេចក្តី រង់ចាំតុលាការសំរេចដល់អង្គសេចក្តី ។

៥_ រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ២.០០០រៀល ដែលដើមចោទបានបង់រួចហើយ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០_ រៀល តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៧ក្រ ចុះថ្ងៃ ទី ០៨.០២.១៩៩៣ ។

៦_ សេចក្តីសំរេចនេះមានប្រសិទ្ធិភាពអនុវត្តភ្លាមពុំបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ ច្បាប់ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៣២ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ១៩៩៩ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ក. ទទួលពាក្យបណ្តឹងចុះថ្ងៃទី ១៣.០៥.៩៨ និងសំណូមពរនាពេលសវនាការ

--- ---

របស់ដើមចោទឈ្មោះ ម៉ែន សម្បត្តិ, លី ប៊ុនឃៀង, ឈុក អ៊ីម, ជា ចំរាង់ និង ឈ្មោះ លឹម គឹមសា ប្តឹងសុំអោយចុងចម្លើយឈ្មោះ យួន សេង អនុវត្តតាមកិច្ចសន្យាសំរុះសំរួលចុះថ្ងៃទី ២៧-០៦.៨៧ និង ប្តឹងសុំអោយបន្ទាបដំបូលសង្កសី ជញ្ជាំងថ្មីប្រូស៊ីម៉ង់ត៍ដែលមានទីតាំងទំនាស់ស្ថិតនៅក្រុម១១ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

ខ- ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១២.១២.៨០ របស់ដើមចោទឈ្មោះ ម៉ែន សម្បត្តិ, លី ប៊ុនឃៀង, ឈុក អ៊ីម, ជា ចំរាង់ និង ឈ្មោះ លឹម គឹមសា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

គ- ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ០៥.០២.៨៩ របស់ចុងចម្លើយឈ្មោះ យួន សេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

ឃ- ទទួលសំណូមពររបស់ចុងចម្លើយឈ្មោះ យួន សេង ប្តឹងសុំរក្សាទុកជញ្ជាំងទំនាស់ និង ប្តឹងសុំរក្សាទុកដំបូលជញ្ជាំងថ្មីប្រូស៊ីម៉ង់ត៍នៅភាពដូចដែល ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្លូវនឹងគតិច្បាប់ ។

២- ទទួលស្គាល់កំណត់ហេតុសំរុះសំរួលចុះថ្ងៃទី ២៧.០៦.៨៧ របស់គណៈកម្មាធិការជំនាញចំរុះខេត្តបាត់ដំបងទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣- អោយចុងចម្លើយឈ្មោះ យួន សេង គោរព និង អនុវត្តតាមកំណត់ហេតុសំរុះរួលចុះថ្ងៃទី ២៧.០៦.៨៧ របស់គណៈកម្មាធិការជំនាញចំរុះខេត្តបាត់ដំបងគឺជញ្ជាំងទំនាស់ត្រូវធ្វើរនាំងពីចរឹងដែក ចាប់ពីជ្រុងទ្វារខាងលិចរបស់ឈ្មោះ ម៉ែន សម្បត្តិ ទៅដល់ជញ្ជាំងផ្ទះរបស់ចុងចម្លើយឈ្មោះ យួន សេង ដោយអោយចុងចម្លើយឈ្មោះ យួន សេង ចេញថវិការសាងសង់ដោយខ្លួនឯងតាមបច្ចេកទេស និង ការអនុញ្ញាតិអោយសាងសង់ពីសមត្ថកិច្ចជំនាញដូចមានចែងក្នុងអនុក្រឹត្យលេខ ៨៦អនក្របក ចុះថ្ងៃទី ១៩.១២.៨៧ របស់រាជរដ្ឋាភិបាលកម្ពុជាចាប់ពីថ្ងៃដែលសាលក្រមចូលជាស្ថាពរ ។

៤- អោយចុងចម្លើយឈ្មោះ យួន សេង បន្ទាបដំបូលជញ្ជាំងថ្មីប្រូស៊ីម៉ង់ត៍ដែលមានទំនាស់ រឺ រៀបចំទៅតាមការអនុញ្ញាតិរបស់សមត្ថកិច្ចជំនាញលើទំហំ, កំពស់, ប្រវែងទទឹងបណ្តោយដែលមានទីតាំងតាមគំនូសប្លង់បង្ហាញទីតាំងដំបូល និង ជញ្ជាំងទំនាស់នៅផ្ទះលេងជាន់ទី១ ក្រុម១១ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ចុះថ្ងៃទី២២.១២.៩៨ ដូចមានចែងក្នុងអនុក្រឹត្យលេខ ៨៦អនក្របក ចុះថ្ងៃទី ១៩.១២.៨៧ របស់រាជរដ្ឋាភិបាលកម្ពុជា ចាប់ពីថ្ងៃដែលសាលក្រមចូលជាស្ថាពរ ។

តាមមាត្រា ២, ១៥ និង ១៨ នៃអនុក្រឹត្យលេខ ៨៦អនក្របក ចុះថ្ងៃទី ១៩-១២-៨៧ របស់រាជរដ្ឋាភិបាលកម្ពុជា និង តាមមាត្រា ៣, ៣ និង ២៩ នៃក្រឹត្យច្បាប់លេខ ៣៨ក្រច ចុះថ្ងៃទី ២៨.១០.១៩៨៨ ។

៥- អោយចុងចម្លើយឈ្មោះ យួន សេង បង់ប្រាក់ប្រដាប់ក្តី ពន្ធចុះបញ្ជីក្តី និង

--- ---

ពន្ធហ៊ីង ១.៨០០៛ រង្វាន់ក្រឡាបញ្ជីការកាន់ចាប់ប្រាក់ ២០០៛ ចំណាយស៊ើបសួរ ៥.០០០៛ សរុប ៧.០០០៛ ។ ប្រាក់នេះបានកាត់យកពីប្រាក់ចំនួន ៧.០០០៛ ដែលដើមចោទបានបង់រួចហើយ កាលបើបណ្តឹងឧទ្ធរណ៍អោយចុងចម្លើយសងប្រាក់នេះទៅដើមចោទវិញ ។

តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៧ក្រ ចុះថ្ងៃទី ០៨.០២.៩៣ ។

៦- សាលក្រមនេះជំនុំជំរះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងឧទ្ធរណ៍ ២ខែ គិតពីថ្ងៃប្រកាសសាលក្រមនេះ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣៤ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៩ របស់ឈ្មោះ ម៉ែន សម្បត្តិ ដែលប្តឹងជំទាស់នឹងសាលក្រមលេខ ៣២ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់តុលាការខេត្តបាត់ដំបងត្រង់ចំណុចទាំងមូលនៃសេចក្តីសំរេច ។

បានឃើញសាលដីកាលេខ ៤៥៨ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលបណ្តឹងឧទ្ធរណ៍របស់ចុងចម្លើយចុះថ្ងៃទី ១៨.៣.៩៩ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- ទទួលបណ្តឹងឧទ្ធរណ៍របស់ដើមចោទ ចុះថ្ងៃទី ០៧.៤.១៩៩៩ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣- ដំកល់សាលក្រមលេខ ៣២ ចុះថ្ងៃទី ១០.២.១៩៩៩ របស់តុលាការខេត្តបាត់ដំបងទុកជាបានការពេញទាំងមូល ។

៤- បង្គាប់អោយឈ្មោះ យួន សេង សងប្រាក់ជំងឺចិត្ត និង ការខាតបង់ចំនួន ១៥០០.០០០រៀល "មួយលានប្រាំសែនរៀល" ទៅអោយដើមចោទ ។ សំណូមពរលើសពីនេះបដិសេធចោល ។

៥- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលឈ្មោះ ម៉ែន សម្បត្តិ បានបង់ទុករួចហើយគឺ : ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ីង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីការកាន់ចាប់ប្រាក់ ៤៥០រៀល ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ៥.០០០រៀល និង ចំណាយលើអាជ្ញាធរតុលាការ ៥.០០០រៀល សរុប ១៣.០០០រៀល ។

កាលបើផុតកំណត់ប្តឹងសាទុក្ខ បង្គាប់អោយឈ្មោះ យួន សេង សងប្រាក់១៣.០០០៛ នេះទៅអោយឈ្មោះ ម៉ែន សម្បត្តិវិញ និង បង្គាប់អោយបង់ពន្ធសមាមាត្រប៉ែន្តមួយភាគរយលើទឹកប្រាក់ដែលតុលាការបានសំរេចក្នុងចំណុចទី៤។ ប្រាក់ពន្ធនេះសំរាប់ជាប្រយោជន៍ថវិការរដ្ឋ ៨០ភាគរយ និង ២០ភាគរយ ជាប្រយោជន៍ក្រឡាបញ្ជីទូទាំងប្រទេស ។

៦- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខ ១ខែ តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៥៩ ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់

--- ---

ឈ្មោះ តាន់ អេង បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៥៥៨ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ-១៩៩៨ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី២៧.៣.២០០០ របស់ឈ្មោះ យួន សេង ។

បានឃើញសារណាតបចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ ២០០០ របស់ឈ្មោះ ម៉ែនសម្បត្តិ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីកាលេខ ៥៥៨ ចុះថ្ងៃទី ១៥.៧.៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ខ្លះ ខុសឆ្គងខ្លះ ។

បានស្តាប់ចម្លើយឈ្មោះ តាន់ អេង ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខដែលបានឆ្លើយនៅពេលសវនាការថា : ខ្លួនពុំសុខចិត្តនឹងការទាមទារជំងឺចិត្តរបស់ឈ្មោះ យួន សេង ទេ ។ ចំពោះបញ្ហាជញ្ជាំងផ្ទះទំនាស់នេះគឺខ្លួនបានសាងសង់នៅលើដីកម្មសិទ្ធិរបស់ខ្លួន ។

ក្រឡាបញ្ជីបានឡើងអានសារណារបស់ឈ្មោះ ម៉ែន សម្បត្តិ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការហើយ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់លោក តាន់ អេង និង សារណារបស់លោក ម៉ែន សម្បត្តិ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា : បណ្តឹងសាទុក្ខលេខ ៣៥៩ ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ១៩៩៨ របស់លោក តាន់ អេង តំណាងអោយចុងចម្លើយធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៥ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា : តំណាងចុងចម្លើយក៏ទទួលស្គាល់ដែរថាក្នុងការសាងសង់នេះ ចុងចម្លើយពុំបានអនុវត្តតាមកំណត់ហេតុសំរុះសំរួលចុះថ្ងៃទី ២៧. ខែមិថុនា ឆ្នាំ ១៩៩៦ ហើយការលើកឡើងរបស់តំណាងចុងចម្លើយក្នុងសារណារបស់ខ្លួនថាពេលសាងសង់ភាគីដើមចោទក៏បានឯកភាព ហើយមិនតវ៉ានោះពុំមានភស្តុតាងគួរអោយតុលាការជឿបានឡើយ ។

- យល់ឃើញថា : ការដែលសាលាឧទ្ធរណ៍សំរេចបន្ថែមដោយអោយចុងចម្លើយសងជម្ងឺចិត្តទៅដើមចោទដោយសំអាងថាការប្តឹងឧទ្ធរណ៍របស់ចុងចម្លើយ ធ្វើអោយខាតបង់ផលប្រយោជន៍របស់ដើមចោទនោះជាការភ័ន្តច្រឡំ ពីព្រោះថា សំណើរសុំនេះជាសំណើរថ្មីដែលតុលាការថ្នាក់ក្រោមពុំទាន់បានពិចារណានៅឡើយ ម្យ៉ាងទៀតសិទ្ធិប្តឹងឧទ្ធរណ៍ពីសេចក្តីសំរេចរបស់តុលាការថ្នាក់ក្រោមជាសិទ្ធិដែលគូភាគីនៃរឿងក្តីមានតាមការកំណត់នៃច្បាប់ ។

--- ---

- យល់ឃើញថា ៖ លោក ម៉ែន សម្បត្តិ បានផ្ញើសារណាការពារទៀងក្តីរបស់លោកជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា ៖ សាលដីការដ្ឋប្បវេណីលេខ ៤៥៨ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ លើកលែងចំណុចស្តីពីជម្ងឺចិត្តដែលគប្បីបដិសេធចោល ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខលោក តាន់ អេង

កំបាំងមុខលោកម៉ែន សម្បត្តិ ចាត់ទុកជាចំពោះមុខ

៙៙៙

១_ ទទួលបណ្តឹងសាទុក្ខលេខ ៣៥៩ ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់លោក តាន់ អេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែគតិច្បាប់ត្រូវខ្លះ ខុសខ្លះ ។

២_ តម្កល់សាលដីការដ្ឋប្បវេណីលេខ ៤៥៨ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងចំណុចទី២ , ៤ និង ពន្ធសមាមាត្រដែលត្រូវទុកជាមោឃៈ ។

៣_ បដិសេធសំណុំរឿងរដ្ឋប្បវេណីលេខ ១០៣ ចុះថ្ងៃទី ០១ ខែ មិនា ឆ្នាំ២០០០ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីលើចំណុចទី២ , ទី៤ និង ចំណុចស្តីពីពន្ធសមាមាត្រនៃសាលដីការដ្ឋប្បវេណីលេខ ៤៥៨ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

៤_ កាត់យកប្រាក់ប្រដាប់ក្តីចំនួន ១៦.០០០រៀល ដែលលោក យួន សេង បានបង់រួចហើយគឺ ៖

- ពន្ធចុះបញ្ជីក្តី និង ពន្ធហឹងចំនួន ៥.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជាររង្វាន់ក្រឡាបញ្ជីកានហិបប្រាក់ ,

- ចំណាយក្នុងកិច្ចប្រគល់ដីការកោះចំនួន ១៥.០០០រៀល សរុប១៩.០០០រៀល

៥_ សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០១ ។